**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆមាសទី១ ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆមាសទី១ ឆ្នាំ២០១៧នេះ ដោយសារស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អប្រសើរក្នុងទូទាំងប្រទេស នោះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ៥០,៤៨% នៃផែនការ ២ ៤៩៦ ៧៩០ហ.ត និងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ផងដែរបើប្រៀបធៀបនឹងឆ្នាំមុន។ ប៉ុន្តែនៅតាមបណ្តាខេត្តមួយចំនួនគឺទទួលរងនូវផលប៉ះពាល់ពីជំនន់ទឹកភ្លៀង និងការធ្លាក់ចុះនៃតម្លៃកសិផលជាដើម។ ជាការកត់សម្គាល់ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មគឺមាននិន្នាការកើនឡើង ៩១,១៧% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របីមាន ៨,៨៣%។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល ក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួងព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្មដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ដោយឡែកក្រសួងបានរៀបចំកិច្ចប្រជុំក្រុមការងារកសិកម្ម និងកសិ-ឧស្សាហកម្មដើម្បីចូលរួមចំណែកដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងឡាយដែលជាក្តីកង្វល់របស់វិស័យឯកជនរួមទាំងកសិករដែលចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ រួមទាំងកិច្ចប្រជុំផ្សេងៗទៀតពាក់ព័ន្ធនឹងការធ្លាក់ចុះនៃតម្លៃទីផ្សារកសិផលផងដែរ។ ម្យ៉ាងទៀត ព្រឹត្តិការណ៍សំខាន់ៗក្នុងឆមាសទី១ ឆ្នាំ២០១៧នេះគឺ ការរៀបចំសន្និបាតកសិកម្មទូទាំងប្រទេស ការត្រៀមរៀបចំមច្ឆទិវានិងរុក្ខទិវាតាមប្រពៃណី។ ទន្ទឹមនឹងនេះក្រសួងក៏បានទទួលជួបសវនាការជាមួយអង្គទូត និងដៃគូអភិវឌ្ឍន៍នានាតាមវិស័យនីមួយៗរួមទាំងការចូលរួមកិច្ចប្រជុំសំខាន់ៗ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលផ្សេងៗទាំងក្នុង និងក្រៅប្រទេសជាច្រើនផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០១៧នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះរដូវវស្សាឆ្នាំ២០១៧

#### ១.១ ផលិតកម្មដំណាំស្រូវ

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ១ ៦៨៩ ៨៤៩ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៥៤ ២៧៦ហ.ត និងដោយគ្រឿងយន្តកសិកម្មមានចំនួន ១ ៦៣៥ ៥៧៣ហ.ត លើសឆ្នាំមុន ២០៧ ៤១៣ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១៧ ៥៤៦ហ.ត លើសឆ្នាំមុន ៤ ០៥៤ហ.ត

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

○ ផ្ទៃដីសន្ទូង និងព្រោះសម្រេចបានចំនួន ១ ២៦០ ២៨២ហ.ត ស្មើនឹង៥០,៤៨% នៃផែនការ ២ ៤៩៦ ៧៩០ហ.ត លើសឆ្នាំមុនចំនួន ២១៩ ៥៥៦ហ.ត។

### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៦៥១ ៨០០ហ.ត ស្មើនឹង ៩១,៩២% នៃផែនការ ៧០៩ ០៦០ហ.ត តិចជាងឆ្នាំមុនចំនួន ៣ ៨៨០ហ.ត

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៣៧ ៨៦០ហ.ត ស្មើនឹង ៣៣,៩៧% នៃផែនការ ១១១ ៤៤០ហ.ត តិចជាងឆ្នាំមុនចំនួន ៤ ៩៨៦ហ.ត។

### ២ ការនាំចេញអង្ករ

ក្នុងខែមិថុនា ឆ្នាំ២០១៧នេះ ការនាំអង្ករចេញតាមរយៈច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ៣០ ៩២៥ តោន ដែលមានការថយចុះចំនួន ២ ៩៣៧តោន (-៩,៥០%) ធៀបនឹងបរិមាណនាំចេញក្នុងខែមិថុនា ឆ្នាំ២០១៦។ សរុបរយៈពេល៦ខែដើមឆ្នាំនាំចេញបានចំនួន ២៨៨ ៥៦២តោន (៦ខែដើមឆ្នាំមុននាំចេញបានចំនួន ២៦៨ ១៩០តោន (+៧,៦០%)) ទៅកាន់ទិសដៅចំនួន ៥៦ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១ (៩៤ ៧២០តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៣៧ ៣២១តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (២៥ ៦៣៩តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៤ (២១ ២៦៩តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (១៤ ៨៩៤តោន) ប្រទេសប៊ែលហ្ស៊ិកឈរលំដាប់ទី៦ (១១ ៤៣២តោន) ប្រទេសឆេកឈរលំដាប់ទី៧ (៩ ៥០៧តោន) ប្រទេសកាបុងឈរលំដាប់ទី៨ (៨ ៨៨២តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៩ (៨ ១៣០តោន) និងប្រទេសអ៊ីតាលីឈរលំដាប់ទី១០ (៧ ០៩៩តោន)។ បច្ចុប្បន្នការនាំចេញអង្ករមានចំនួន ៧២ក្រុមហ៊ុន។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានប្រចាំខែនេះ (តោន) | បញ្ចេញលក់ប្រចាំខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥៨៣ | ៧៧៦ | ២២៤ | ១៥០ |
| | **សរុប I** | **៥៨៣** | **៧៧៦** | **២២៤** | **១៥០** |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១ ៩៣៤ | ១៥ ៣៥៩ | ២៨ ៥១៥ | ៥ ៣៩២ |
| ២ | ក្រុមហ៊ុន ស៊ីហ្វាប់ប៊េលីមីធីត (រតនគិរី) | ៧៩ | ២ ៥៥៨ | ៤៨ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១ ០១០ | ២ ១២១ | ៥៤៣ | ៣៧៨ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ១១០ | ៥ ៦៣៤ | ១ ៧០៤ | ១ ២៩៥ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣ ៩៩៧ | ៨ ៦៦១ | ១ ៦៥០ | ១ ៣៥៦ |
| ៦ | ក្រុមហ៊ុន ស្និហ្វរីសសស់ (ស្នួល) | ២ ៦២៨ | ៤ ៤០៦ | ១ ១៥៧ | ៧២៧ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១ ៨៨២ | ៣ ៣៩០ | ៤៣៣ | ៤៣២ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្ដូង) | ៣ ៣២៧ | ៥ ៩២៤ | ៧៩៦ | ៧០៨ |
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៤ ១៣៤ | ៤ ៧៩៨ | ២ ០០៩ | ១ ២១៨ |
| | **សរុប II** | **៣២ ១០១** | **៥២ ៨៥១** | **៣៦ ៨៥៥** | **១១ ៥០៦** |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៤៤ ៦០០ | ២២៥ ៩០០ | ១១ ៨០០ | ១១ ៣០០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៩៥ ៤០០ | ១៥៤ ៣០០ | ៣២ ២០០ | ៣១ ៦០០ |
| | **សរុប III** | **១៤០ ០០០** | **៣៨០ ២០០** | **៥៥ ៣០០** | **៥៣ ៩០០** |
| | **សរុប I+II+III** | **១៧២ ៦៨៤** | **៤៣៣ ៨២៧** | **៩២ ៣៧៩** | **៦៥ ៥៥៦** |

• គួរកត់សម្គាល់ថា សម្រាប់ឆមាសទី១ ឆ្នាំ២០១៧នេះ តម្លៃកៅស៊ូជាមធ្យម ១ ៤៥០ដុល្លារអាមេរិកក្នុងមួយតោន។

**២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- បានបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូស្តីពី ការគ្រប់គ្រងសមាសភាពចម្រៃនិងជំងឺ ដល់ប្រជាកសិករនៅខេត្តត្បូងឃ្មុំ
- បានវាស់ទំហំដើមដើម្បីតាមដានការលូតលាស់លើចម្ការពិសោធន៍នីមួយៗ
- បានលាបថ្នាំរំញោចចម្ការពិសោធន៍ក្នុងនិងក្រៅស្ថានីយចំនួន ១៥ចម្ការពិសោធន៍
- បានថែទាំសមូហកម្មពូជដំណាំគម្របដី១៧ប្រភេទ និងបាញ់ថ្នាំការពារនិងព្យាបាលជំងឺផ្កាកូលាប ៤៨ហ.ត
- បានថែទាំសមូហកម្មពូជដំណាំគម្របដីចំនួន ១៧ប្រភេទ និងថ្នាលបណ្តុះកូនកៅស៊ូ
- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន ៣០ភាគសំណាក សម្រាប់ធ្វើតេស្តត្រួតពិនិត្យគុណភាពរោងចក្រ
- បានសហការជាមួយអង្គការ UNIDO ដើម្បីអនុវត្តសកម្មភាពទទួលស្គាល់ការធ្វើតេស្ត Rubber-Based and Rubber products tests
- វិភាគ DRC តាមមេត្រូឡាក់ តាមការដុតរក TSC និងការវិភាគតាមមន្ទីរពិសោធន៍
- បានធ្វើតេស្តអន្តរមន្ទីរពិសោធន៍ចំនួន ០២លើក ជាមួយ IRA។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមជាអ្នកសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីប្រតិបត្តិស្តង់ដារអន្តរក្រសួងសម្រាប់ការអង្កេត និងឆ្លើយតបចំពោះការរាតត្បាតជំងឺបណ្តាលមកពីការពុលចំណីអាហារ
- បានចូលរួមប្រជុំពិភាក្សាតាមប្រព័ន្ធស្កាយពីប្រទេសហ្វីលីពីនរវាងក្រុមការងារអន្តរក្រសួងសុវត្ថិភាពចំណីអាហារ នៅក្រសួងសុខាភិបាលស្តីពី ការលើកគម្រោងផែនការសកម្មភាពសម្រាប់ឆ្នាំ ២០១៨
- បានចូលរួមសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការអនុវត្តស្តង់ដារលើការឆ្លើយតបការផ្ទុះជំងឺដែលកើតឡើងថ្មីៗពីការពុលអាហារនៅខេត្តប៉ៃលិន
- ក្រុមការងារបច្ចេកទេសនៃមន្ទីរពិសោធន៍បានដំឡើងនិងធ្វើតេស្តម៉ាស៊ីនបិទទឹកនិងម៉ាស៊ីនវិភាគឬដកយកអាស៊ីតនុយក្លេអ៊ិច
- បានរៀបចំសេចក្តីព្រាងប្រកាសនិងបានពិភាក្សាស្តីពីការចុះបញ្ជីអ្នកប្រមូលទិញផលិតផលកសិកម្មនិងអ្នកដាំដុះ អ្នកចិញ្ចឹមសត្វ និងអ្នកកែច្នៃផលិតផលកសិកម្ម
- បានបើកកិច្ចប្រជុំពិភាក្សាស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួល កិច្ចសន្យាផលិតកម្មកសិកម្មដោយមានការចូលរួមពីបណ្តាក្រសួង ស្ថានប័នពាក់ព័ន្ធ និងវិស័យឯកជននានា
- បានរៀបចំគម្រោងចំនួន ០២៖(១)ស្តីពីការសិក្សាស្រាវជ្រាវ និងវាយតម្លៃលើគុណភាព និងសុវត្ថិភាពនៃផលិតផលធញ្ញជាតិ (Research Study and Evaluation on Quality and Safety of Cereal and Grain Commodities) (២) ស្តីពីការគ្រោងចំណាយក្នុងការវិភាគរកកាកសំណល់ Tricyclazole ក្នុងស្រូវនិងអង្ករកម្ពុជា ។

## ៤ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្ត និងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព។ (ខ) ការងារឡជីវឧស្ម័ន បន្តចុះអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ (គ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេច

ប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង CIAT។

### ៤.២ ការងារបសុព្យាបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** ក្នុងឆមាសទី១ ឆ្នាំ២០១៧នេះ រាជធានី-ខេត្តចំនួន២២ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ២០ ២១៣លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទូទាំងប្រទេសបានចំនួន ៤៩០ករណី ដោយបានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ៥៩៦គីឡូក្រាម និងផាកពិន័យ ៥៨លានរៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនសត្វរស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញដើម្បីការពារការឆ្លងរាលដាលនៃជំងឺផ្សេងៗ។
- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត។ រហូតមកទល់ពេលនេះសត្តឃាតដ្ឋានទទួលបានគោលការណ៍អនុវត្តចំនួន ១៥៥កន្លែង និងបានចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស ដើម្បីសុខុមាលភាពសាធារណៈ។
- **ការងារនីតិកម្មនិងវិវាទ៖** កំពុងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វទៅតាមលំដាប់អាទិភាពមានជាអាទិ៍៖ សេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងគ្រប់គ្រងសត្តឃាតដ្ឋាន ព្រមទាំងបានប្រជុំជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំចងក្រងអនុក្រឹត្យ និងសៀវភៅសម្រាប់ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។ លើសពីនេះទៀត ក្រសួងបានរៀបចំកិច្ចប្រជុំក្រុមការងារកសិកម្ម និងកសិ-ឧស្សាហកម្មដើម្បីចូលរួមចំណែកដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងឡាយដែលជាក្តីកង្វល់របស់វិស័យឯកជនរួមទាំងកសិករដែលចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ។

### ៤.៣ ការងារស្រាវជ្រាវ៖

- **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ២ ១២៣វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី។ ជាក់ស្តែងក្នុងឆមាសទី១ ឆ្នាំ២០១៧នេះ មានផ្ទុះជំងឺផ្តាសាយបក្សី១ករណីនៅភូមិបាយ៉ាប ឃុំបាសាក់ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ បន្ទាប់ពីស្ថានភាពជំងឺស្ងប់ស្ងាត់ ក្រសួងបានប្រកាសរំសាយតំបន់ផ្ទុះជំងឺដោយអនុញ្ញាតឱ្យប្រជាជនចិញ្ចឹមបក្សីឡើងវិញជាប្រក្រតី។
- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១១៥ក្បាល ក្នុងនោះគោបា១ក្បាល គោប្រាម៉ាន់កាត់៦ក្បាល គោជំទង់៣៨ក្បាល គោបៅដោះ៣០ក្បាល គោកំផែងសែន ៣៩ក្បាល គោងាប់១៧ក្បាល គោកើតថ្មី០១ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ៥៥៦ក្បាល ក្នុងនោះជ្រូកបា៨ក្បាល ជ្រូកមេ៧១ក្បាល កូនជ្រូក២៣៧ក្បាល កូនជ្រូកលក់២៤០ក្បាល ជ្រូកងាប់ ២៤ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតីនិងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៤.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ រួមទាំងពង្រឹងយន្តការផ្សព្វផ្សាយតាមរយៈភ្នាក់ងារសុខភាពសត្វភូមិ។

## ៥ ផ្នែកព្រៃឈើ

### ៥.១ ការងារព្រៃឈើ

- បានរៀបចំចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ១២កន្លែង មានផ្ទៃដីសរុបចំនួន ៦ ៣៩០ ហ.ត ស្ថិតនៅក្នុងស្រុកក្រគរ និងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

- បានចេញប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ០៣គឺៈ (១)តំបន់ព្រៃសហគមន៍ត្រពាំងទឹម នៅឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប (២)តំបន់ព្រៃសហគមន៍ភ្នំប្រជុំមិត្ត នៅឃុំសំអាង ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង (៣)តំបន់ព្រៃសហគមន៍ដៃគូសំរោង នៅឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

- បានចុះធ្វើសារពើភ័ណ្ឌព្រៃសហគមន៍នៅក្នុងខេត្តមណ្ឌលគិរីចំនួន ០២កន្លែង ដែលក្នុងនោះព្រៃសហគមន៍ពីងប្រង់ក្លង់ពេសចូចំនួន ២៦ឡូតិ៍ មានផ្ទៃដីចំនួន ៥១៣ហ.ត និងព្រៃសហគមន៍អូរចុងណាចចំនួន ៤២ឡូតិ៍ មានផ្ទៃដីចំនួន ៧០៥ហ.ត និងវិភាគទិន្នន័យសារពើភ័ណ្ឌព្រៃឈើដើម្បីរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍

- បានបើកវគ្គផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ការគ្រប់គ្រង និងការអនុវត្តលិខិតបទដ្ឋានច្បាប់សហគមន៍ព្រៃឈើ ផលប្រយោជន៍ព្រៃសហគមន៍ និងនីតិវិធីទប់ស្កាត់បទល្មើសព្រៃសហគមន៍ចំនួន ០៨វគ្គ ដល់សហគមន៍ព្រៃឈើចំនួន ០៨កន្លែង នៅក្នុងខេត្តចំនួន ០៤គឺៈ ខេត្តមណ្ឌលគិរី ស្វាយរៀង ពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ ដែលមានអ្នកចូលរួមសរុបចំនួន ២៣៩នាក់

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តនិងយានយន្តជូនដល់ក្រុមហ៊ុន និងអតិថិជនសរុបចំនួន ៣៦គ្រឿង

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ២១ និងអតិថិជនចំនួន ០១នាក់ មានឈើហ៊ុបមូលចំនួន ២៦ ៨៩៥ម³ ឈើអារចំនួន ៧៩៨ម³ ឈើលេខ ០១ ចំនួន ៨ ០០០ម³ ឈើជ្រៀងចំនួន ១ ៨៣៩ម³ កូនក្រឡឹងចំនួន ៥៩៨ម³ កូនឈើចំនួន ៦៦៨ ០៦៨ដើម អុសចម្រុះចំនួន ៥៧ ៧៩៤ស្ទែរ ជ័រទឹកចំនួន ៦៣៨តោន ឬស្សីចំនួន ៥០៣តោន និងជន្លង់ម្រេចចំនួន ៦ ៥៥៥ដើម។

### ៥.២ ការងារអភិរក្សសត្វព្រៃ

- បានធ្វើការសិក្សាស្រាវជ្រាវអំពីកត្តាគម្រាមកំហែងចំពោះសត្វព្រៃក៏ដូចជាសត្វដំរីនៅតំបន់ជួរភ្នំក្រវាញ និងបំពាក់ម៉ាស៊ីនថតស្វ័យប្រវត្តិនៅតំបន់មានវត្តមានដំរីព្រៃនៅថ្មបាំង អារ៉ែង វាលតាភូ និងអូរកី នៃខេត្តកោះកុងបានសរុបចំនួន ៤៥គ្រឿង និងទិន្នន័យចំណុចនិយាមកា ប៉ុន្តែម៉ាស៊ីនថតចំនួន ០៣គ្រឿង ត្រូវបានគេវាយបំបែកនិងដោះយក

- ហ្វូងដំរីបានចូលស៊ីដំណាំប្រជាពលរដ្ឋចំនួន ២៧គ្រួសារ អស់ចេក ១៨១៦គុម្ព ស្វាយ ០៣ដើម ខ្នុរ ៦៧ដើម ធុរេន ០១ដើម ដូង ១៦ដើម ល្ហុង ០៩ដើម ម្នាស់ ១០គុម្ព ផ្លែខ្នុរប្រមាណ ៥៥០ផ្លែ និងផ្លែស្វាយអស់ជាច្រើនផ្លែ

- បានប្រមូលសំណាកលាមកដំរីព្រៃបានចំនួន ៣៧១សំណាក ក្នុងតំបន់ជួរភ្នំក្រវាញ ហើយត្រូវបានចម្រាញ់យក DNA និង PCR (Polymerase Chain Reaction) នៅមន្ទីរពិសោធន៍សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយលទ្ធផល PCR ត្រូវបានយកទៅវិភាគនៅសាកលវិទ្យាល័យសត្វព្រៃនៃប្រទេសស្កត់លែនបន្តដើម្បីកំណត់ចំនួនដំរី។

### ៥.៣ កសិដ្ឋានចិញ្ចឹម បន្ទាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ០៦ បានគ្រប់គ្រងកសិដ្ឋានចំនួន ០៧ ដែលមានស្វាក្តាមសរុបចំនួន ៣៩ ៩២២ក្បាល ក្នុងនោះកូនកើតក្នុងខែសរុបមានចំនួន ៣ ៦០៩ក្បាល ហើយចំនួនសត្វស្វាក្តាមជំទង់នាំចេញមានចំនួនសរុប ២ ៣១២ក្បាល

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៧នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ២៨៥ក្បាល (បក្សីចំនួន ៥០ប្រភេទ ថនិកសត្វចំនួន ៤៥ប្រភេទ និងល្មូនចំនួន ១៤ប្រភេទ)សង្គ្រោះសត្វថ្មីចំនួន ៨៨៩ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ១៥៣ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៨០៩ក្បាល ជួសជុលផ្លូវ លុបសម្អកមាន់ និងក្រាលក្រួសក្រហមបានប្រវែង ៧ ៨៨៩ម និងកាប់ឆ្ការអនាម័យព្រៃបានទំហំ ១៤ហ.ត។ ដោយឡែកគម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិក្រុមល្បាតសហគមន៍ចំនួន ៣០នាក់ បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ០៥ គឺៈ នៅអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)។ បានតាមដានពិនិត្យប្រចាំឆ្នាំនៅតំបន់អភិរក្សហើយជួបប្រទះក្រពើភ្នំផ្ទាល់ចំនួន ១២ក្បាល ស្លាកស្នាម ១៧កន្លែង និងលាមកចំនួន ៣៨ដុំ។ បានលែងក្រពើភ្នំចំនួន ០៦ក្បាលនៅស្ទឹងកំពង់តាជ័យ ខេត្តកោះកុង ហើយបានចែកប្រដាប់ក្មេងលេងចំនួន

២០ឈុត និងសៀវភៅរឿងនិទានពីបរិស្ថានចំនួន ០៧ក្បាល ដល់សាលាបឋមសិក្សាភូមិពោធិបឹង និងបានតាមដានក្រពើភ្នំ ដែលលែងដោយប្រើឧបករណ៍ Radio tracking បានជួបក្រពើភ្នំចំនួន ០២ក្បាល។

### ៥.៤ ការងារដាំដើមឈើ

- ការចុះសិក្សាស្រាវជ្រាវ និងធ្វើសារពើភ័ណ្ឌទីតាំងដីសម្រាប់ការងារដាំឈើ ដើម្បី ចុះហត្ថលេខាលើផែនទីទីតាំងស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើ ក្នុងខេត្តចំនួន ០៦ រួមមាន៖ ខេត្តក្រចេះ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ឧត្តរមានជ័យ និងកំពង់ធំ។ ក្រុមការងារបានបង្កើតស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ២៧ទីតាំង លើផ្ទៃដីសរុបចំនួន ៣០១ ៩៨២ហ.ត ដោយបានទទួលស្គាល់ពីអាជ្ញាធរដែនដីតាមខេត្តនីមួយៗ

- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ៤០៧ ៨១៩ដើម និងចែកជូនប្រជាពលរដ្ឋចំនួន ៨០ ២៣៣ដើម និងការងារថែទាំចម្ការឈើចាស់

- ការអភិរក្សក្រៅតំបន់តាមរយៈការរៀបចំចម្ការពូជប្រភេទឈើក្នុងស្រុកថ្មីទំហំ ៥០ហ.ត ដែលស្ថិតនៅក្នុងខេត្តកំពង់ធំ កំពុងតែដាំដុះប្រភេទឈើគ្រញូងបានទំហំ ០៨ហ.ត និងប្រភេទឈើផ្ចង់បានទំហំ ០២ហ.ត សកម្មភាពបេះប្រមូលគ្រាប់ពូជឈើរងការគម្រាមកំហែងក្នុងស្រុក បានចុះពិនិត្យនិងប្រមូលព័ត៌មានប្រភពគ្រាប់ពូជដែលអាចផ្តល់គ្រាប់ពូជក្នុងឆ្នាំ២០១៧

- ការបង្កើតឡូតិ៍បង្ហាញកសិ-រុក្ខកម្មលើទំហំ ១៥ហ.ត ដែលស្ថិតនៅខេត្តកំពង់ធំ បានធ្វើការឈូសឆាយសម្អាតដីព្រៃរេចរឹល ហើយបាននិងកំពុងត្រៀមដាំកូនឈើគ្រញូង អាកាស្យា គគីរ ផ្ចង់ ឈើទាល និងប្រភេទដំណាំរួមមាន៖ សណ្តែក ដំឡូងមី និងឪឡឹក

- បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំរុក្ខទិវាថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៧ នៅឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាល។

### ៥.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ចុះពិនិត្យដល់ទីតាំងជាក់ស្តែងតាមលក្ខណៈបច្ចេកទេសចំពោះក្រុមហ៊ុនចំនួន ២២ ដែលបានស្នើសុំបន្តសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើ និងក្រុមហ៊ុនចំនួន ០៤ ដែលបានស្នើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ០៧ កន្លែង

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ០៨ មានបរិមាណឈើកែច្នៃចំនួន ៦ ៣៦៤ម$^{៣}$ ជ័រទឹកចំនួន ៨៨តោន និងធ្យូងអាកាស្យាចំនួន ២៧តោន ព្រមទាំងបានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលចំនួន ០៤ក្រុមហ៊ុនដែលមានបរិមាណផលិតផលឈើកែច្នៃសរុបចំនួន ៣ ២០៩ម$^{៣}$ ក្រុមហ៊ុនចំនួន ០៥ បាននាំចេញផលិតផលវានទេវតា និងឈើកែច្នៃទៅក្រៅប្រទេសមានបរិមាណសរុបចំនួន ៤ ៧៤១ម$^{៣}$ និងជ័រទឹកចំនួន ៦៨តោន ក្រុមហ៊ុនចំនួន ០៤ បានធ្វើការនាំចូលឈើ Poplar Lumber Radiata MDF Wood Pan Chanfuta Umbila ពីប្រទេសញូហ្ស៊ីលែន ចិន សហរដ្ឋអាមេរិច កូរ៉េ មូហ្សាំប៊ិច និង ប្រទេសនីហ្សេរីយ៉ា សរុបចំនួន ២ ៣៣៧ ម$^{៣}$ ។

### ៥.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៧នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ១៦ ៩៥៣ ៤៧៧ ០៦១ រៀល និងចំណូលពីសេវាសាធារណៈចំនួន ២ ៧១១ ៥៩៧ ៧៥៤រៀល និង៩៩ ២០៤,៨៥ដុល្លារអាមេរិក។

### ៥.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៧នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន ៦១៥ករណី ដោយពិន័យអន្តរការណ៍ចំនួន ២៣៩ករណី និងបញ្ជូនទៅតុលាការចំនួន ៣៧៦ករណី

- ដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន ២៧៩ម$^{៣}$ ឈើអារចំនួន ១ ៤៦៨ម$^{៣}$ ឈើក្រាក់គ្រញូងចំនួន ២៤ម$^{៣}$ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ៣ ១០២ក្បាល និង៧៦១គីឡូក្រាម អនុផលព្រៃឈើនិងសម្ភារផ្សេងៗមួយចំនួនទៀត និងសំណុំរឿងបទល្មើសកាប់រានដីព្រៃចំនួន ១៨ករណី មានផ្ទៃដីព្រៃឈើដែលកាប់រានចំនួន ៤៩១ហ.ត ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី និងដកហូតរណារយន្តចំនួន ៣៥គ្រឿង

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៦ ផ្នែកជលផល

### ៦.១ អាជីវកម្មនេសាទ

#### ៦.១.១ នេសាទទឹកសាប

- ដាយត្រីធ្វើអាជីវកម្ម អនុវត្តបានចំនួន ៤ ៩៤៥តោន ស្មើនឹង៤១,២១% នៃផែនការ ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៣ ៨៩៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន ១៣០ ៣៥០តោន ស្មើនឹង៣៧,៨៩% នៃផែនការ ៣៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ២ ៦៥០តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន ៣១ ៥០០តោន ស្មើនឹង២១,៨៨% នៃផែនការ ១៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៣ ០០០តោន។

#### ៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៥៦ ៥៧៥តោន ស្មើនឹង៥១,៤៣% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១ ២២៥តោន។

### ៦.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន ៧៨ ៣០៣តោន ស្មើនឹង៤៥,៣១% នៃផែនការ ១៧២ ៨០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៩ ២៥៣តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន ១២០ ០០០ក្បាល ស្មើនឹង៤៨,០០% នៃផែនការ ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៥ ០០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួនប្រមាណ ៦៥ ០០០ ០០០កូន ស្មើនឹង៣៦,១១% នៃផែនការ ២០០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួនប្រមាណ ៥ ០០០ ០០០កូន

- បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំមច្ឆទិវាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧ នៅទំនប់សេកសក ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។

### ៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ អនុវត្តបានចំនួន ២៧ ៥០០តោន ស្មើនឹង៣៣,៥៤% នៃផែនការ ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១ ៣០០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៥ ៨៧០តោន ស្មើនឹង៧៣,៣៨% នៃផែនការ ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៤៥តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៣៥ ០០០ ០០០លីត្រ ស្មើនឹង៧០,០០% នៃផែនការ ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ២ ០០០ ០០០លីត្រ។

### ៦.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ អនុវត្តបានចំនួន ៥ ៣០០តោន ស្មើនឹង៣៥,៣៣% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ២៥០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន ៣ ២០០តោន ស្មើនឹង៦៤,០០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ៤០០តោន។

### ៦.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៧នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ១ ៦៥៣ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១ ៥៥៣ករណី និងសមុទ្រចំនួន ១០០ករណី។

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង ៧០៤ ៤៣២ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន ៨ ៦៧១មាត់ បង្គោល/ចម្រឹងចំនួន ៣៩៤ ៦៨៩ដើម ឧបករណ៍ឆក់ត្រីចំនួន ២៧៤គ្រឿង សម្រាស់ទំហំ ៣៧ ៩៥៨ម៉ែត្រក្រឡា របាំងព្រួលប្រវែង ៣ ៧៦៧ម៉ែត្រ និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ២៨ ១១៥ គ.ក្រ និងពិន័យអន្តរការណ៍ចំនួន ៤២ករណី ស្មើនឹងទឹកប្រាក់ចំនួន ១៦៦ ៥០០ ០០០រៀល

- បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន ១០៥វគ្គ ដោយមានអ្នកចូលរួមចំនួន ៣ ៨១២នាក់។

### ៦.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផលឆមាសទី១ ឆ្នាំ២០១៧ ចំនួន ១ ១០២ ០១៦ ៤៨៣រៀល ស្មើនឹង៣៦,៧៣% នៃផែនការ ៣ ០០០ ០០០ ០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១៤៩ ៥៣៦ ១៤៣រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- លោកនាយកវិទ្យាស្ថាន បានទទួលពានរង្វាន់ជា " **អ្នកវិទ្យាសាស្ត្រឆ្នើម** " សម្រាប់ឆ្នាំ២០១៦ ដែលមានស្នាដៃក្នុងការអភិវឌ្ឍន៍ពូជដំណាំផ្សេងៗ ជាពិសេសពូជស្រូវផ្ការំដួល ដែលបានជាប់ចំណាត់ថ្នាក់លេខ១លើលោករយៈពេល៣ឆ្នាំជាប់គ្នា (២០១២ ២០១៣ និង២០១៤) និងពូជស្រូវសែនពិដោរជាដើម
- បាននិងកំពុងធ្វើពិសោធន៍ចំនួន ៤៩ប្រភេទ នៅ៧៩កន្លែង
- បាននិងកំពុងធ្វើពិសោធន៍បន្សាំពូជលើស្រែកសិករនិងស្រែបង្ហាញចំនួន ២៧១កន្លែង
- បានចែកគ្រាប់ពូជស្រូវក្នុងមួយគ្រួសារចំនួន ៥គ.ក្រជូនដល់កសិករចំនួន ៥៨៣គ្រួសារ ដែលក្នុងនោះនៅខេត្តត្បូងឃ្មុំ កែប កំពង់ឆ្នាំង ពោធិ៍សាត់ និងកំពត សរុបចំនួន ២ ៩១៥គ.ក្រ
- ថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានចំនួន ២៤នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលានិងក្រៅប្រទេសចំនួន ១៣លើក។ មន្ត្រីចំនួន០២រូបបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតនៅប្រទេសកូរ៉េ និងនៅប្រទេសអូស្ត្រាលី និងមន្ត្រីសរុបចំនួន ០៥រូបទៀតបានកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិតនៅក្រៅប្រទេស
- បន្តការងារពិសោធន៍ស្រាវជ្រាវតាមរាជធានី-ខេត្តនិងនៅក្នុងវិទ្យាស្ថាននារដូវវស្សាឆ្នាំ២០១៧
- ចុះពិនិត្យ និងវាយតម្លៃពិសោធន៍នានាក្នុងរដូវវស្សានៅតាមបណ្តាខេត្តគោលដៅ
- បន្តបញ្ចូលទិន្នន័យនិងធ្វើការវិភាគជាបណ្តើរៗរាល់ពិសោធន៍ដែលបានចប់សព្វគ្រប់
- បន្តអភិរក្សពូជស្រូវ ចេកនិងដំណាំផ្សេងៗនៅក្នុងវិទ្យាស្ថាន
- បានរៀបចំពិធីការនិងសម្ភារសម្រាប់ពិសោធន៍រដូវវស្សាឆ្នាំ២០១៧។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ១១០ក្រុមហ៊ុន សរុបចំនួន ១ ០១៧មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ១៣៩ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥១ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣៤ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន ៤២ក្រុមហ៊ុនសរុបចំនួន ២១៧សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ កោះកុង

ព្រះសីហនុ តាកែវ កំពត កំពង់ចាម ព្រៃវែង និងខេត្តស្វាយរៀង ដែលមានសមាសភាពចូលរួមសរុបចំនួន ៣១៩នាក់។

**៨.៤ ការខារអនុវត្តច្បាប់**

- បានធ្វើប្រតិវេទន៍ដល់ក្រុមហ៊ុនចំនួន ៦០ក្រុមហ៊ុន
- ពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២១ ២០០ ០០០រៀល ពីក្រុមហ៊ុនចំនួន ១០ អាជីវករលក់ដុំ និងលក់រាយចំនួន ០៥ដេប៉ូ។

## ៩ ផ្នែករដ្ឋបាល

- ក្នុងឆមាសទី១ ឆ្នាំ២០១៧នេះ បានទទួលលិខិតពីក្រសួង-ស្ថាប័ននានាចំនួន ១ ៨០០ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ១ ៩៥៣ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៨៣៧ច្បាប់ និងចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តរដ្ឋបាល
- បញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៥ ៦៥៥ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៣៦១ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទចំនួន ១១៨ច្បាប់
- បានចេញប្រកាសព័ត៌មានស្តីពីការទប់ស្កាត់ការនាំចូលជ្រូកពីក្រៅប្រទេសមកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការចិញ្ចឹមជ្រូកក្នុងស្រុក
- បានចេញសេចក្តីជូនដំណឹងស្តីពីការនាំចូលសត្វរស់ សាច់សត្វ និងផលិតផលសត្វដើម្បីផ្គត់ផ្គង់បំពេញតម្រូវការសាច់នៅរាជធានីភ្នំពេញ និងបណ្តាខេត្ត ដើម្បីពង្រឹងការគ្រប់គ្រងហានិភ័យនៃការឆ្លងរាលដាលនៃជំងឺសត្វ លើកកម្ពស់គុណភាពសាច់សត្វ និងការពារសុខភាពសាធារណៈប្រកបដោយសុវត្ថិភាព
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំ ពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម) ។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៧៩៤នាក់ ក្នុងនោះនារីចំនួន ១ ៥២៣នាក់ ស្មើនឹង ២២% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៧៧៥នាក់ ក្នុងនោះនារីចំនួន ៧៧៩នាក់ ស្មើនឹង ២៨%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន ៤ ០១៩នាក់ ក្នុងនោះនារីចំនួន ៧៤៤នាក់ ស្មើនឹង ១៨%
- បានតែងតាំងដំឡើងឋានៈ និងសម្រួលភារកិច្ចមន្ត្រីរាជការចំនួន ១៨០នាក់ ក្នុងនោះនារីចំនួន ៤៦នាក់
- បានលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន ១៧នាក់ ក្នុងនោះនារីចំនួន ០៤នាក់
- បានចេញប្រកាសផ្ទេរមន្ត្រីរាជការខាងក្រៅក្រសួងចំនួន ១៧នាក់ ផ្ទេរចេញក្រៅក្រសួងចំនួន ១១នាក់ ផ្ទេរចូលក្នុងក្រសួងចំនួន ០៦នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងមានចំនួន ៦០នាក់
- ត្រៀមរៀបចំប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីដែលក្រសួងមុខងារសាធារណៈបែងចែកឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ១៨៤នាក់
- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកប្រចាំឆ្នាំមានចំនួន ២៨នាក់ ព្យាបាលជំងឺចំនួន ០៦នាក់ និងច្បាប់សម្រាកមាតុភាពមានចំនួន ១៧នាក់
- បានកែសម្រួលលើការប្រែប្រួលស្ថានភាពរដ្ឋបាលពីខែមករា ដល់ខែកក្កដា ឆ្នាំ២០១៧
- បានចេញប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សមានចំនួន ៦១នាក់ ក្នុងនោះនារីចំនួន ០៨នាក់
- បានចេញប្រកាសមន្ត្រីរាជការចូលបម្រើក្នុងការងារក្នុងអង្គភាពដើមវិញមានចំនួន ៣៧នាក់ ក្នុងនោះនារីចំនួន ០៨នាក់
- បានចេញប្រកាសដាក់មន្ត្រីឱ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈមានចំនួន ៨១នាក់

- មន្ត្រីរាជការបានចូលរួមការងារបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសសរុបមានចំនួន ៦៩៧នាក់ ក្នុងនោះនារី ២២២នាក់។

## ១១ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានទទួលធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំលើកទី១២ នៃក្រុមការងារបច្ចេកទេសអាស៊ានស្តីពីការងារស្រាវជ្រាវ និងអភិវឌ្ឍកសិកម្ម និងកិច្ចប្រជុំលើកទី២៤ របស់គណៈកម្មការរួមស្តីពីកិច្ចសហប្រតិបត្តិការអាស៊ានលើប្រព័ន្ធជំរុញផលិតផលកសិកម្ម និងព្រៃឈើ

- បានសម្រួលលិខិតទិដ្ឋការជូនថ្នាក់ដឹកនាំ ដើម្បីចូលរួមបោះឆ្នោតជ្រើសរើសបេក្ខភាពប្រធានមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម

- បានពន្យារទិដ្ឋការស្នាក់នៅរបស់ជំនាញការចំនួន ០៧រូប

- បានស្នើសុំសិទ្ធិប្រទាន ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ីនៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ

- បានរៀបចំសេចក្តីព្រៀងវិសោធនកម្មនៃកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលសហរដ្ឋអាមេរិកសម្រាប់អនុវត្តកម្មវិធី កសិកម្ម និងបរិស្ថាន

- បានរៀបចំសេចក្តីព្រៀងលើអនុស្សរណៈយោគយល់គ្នាស្តីពី លទ្ធកម្មនៃផលិតកម្មកសិកម្ម រវាងកម្ពុជា និងរុស្ស៊ី

- បានសម្រួលលិខិតជូនថ្នាក់ដឹកនាំ និងមន្ត្រីទៅចូលរួមសិក្ខាសាលា សន្និសីទ ទស្សនកិច្ច និងវគ្គបណ្តុះបណ្តាល ចំនួន ៣៧៧នាក់។

## ១២ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១២.១ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ សរុបចំនួន ៨៧៨នាក់ (ស្ត្រី ៣១២នាក់) ក្នុងនោះ និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៦២១នាក់(ស្ត្រី ២១៦នាក់) និងនិស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន ២៥៧នាក់(ស្ត្រី ៩៦នាក់) លើជំនាញ៖ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី
- បានចុះពិនិត្យការសិក្សារៀបចំស្រាវជ្រាវរបស់និស្សិត និងជួយជាបច្ចេកទេសដល់កសិករចំនួន ០៣ខេត្ត
- បានដឹកនាំនិស្សិតធ្វើការពិសោធន៍ត្រី និងបន្លែ
- បាននិងកំពុងផលិតពូជចេកស្វែង(ចេកអត់ត្រយូង) និងចេកក្រមួនដើម្បីចែកជូនកសិករ
- បានបន្តការកែតម្រូវកម្មវិធីសិក្សាឱ្យឆ្លើយតបនឹងទីផ្សារ បទដ្ឋានជាតិ អន្តរជាតិ
- បានបន្តរៀបចំពិសោធន៍ដំណាំស្រូវជប៉ុន និងដំឡូងបារាំង
- បានដឹកនាំនិស្សិតធ្វើការពិសោធន៍ចិញ្ចឹមសត្វ និងការដាំដំណាំ
- បានចុះសិក្សារកពូជឈើព្រៃសម្រាប់ដាំលម្អនៅខេត្តរតនគិរី
- បានបើកវគ្គផ្សព្វផ្សាយកសិកម្ម និងកែលម្អកម្មវិធីសិក្សាជាមួយគម្រោង ASPIRE។

### ១២.២ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៦-២០១៧ សរុបមានចំនួន ៧៨៦នាក់(ស្ត្រី ៣១៨នាក់) រួមមាន៖ និស្សិតអាហារូបករណ៍សរុប ៥៧៧នាក់ (ស្ត្រី ២៧១នាក់) និស្សិតសិក្សាបង់ថ្លៃចំនួន ២០៩នាក់ (ស្ត្រី ៤៧នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិង អភិវឌ្ឍន៍ជនបទ

- បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ ក្នុងនោះកំពុងសហការជាមួយ DTRA ICEBP ដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍

- បានសហការជាមួយទីភ្នាក់ងារ KOICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់សាស្ត្រាចារ្យទៅបន្តការសិក្សាថ្នាក់

អនុបណ្ឌិតនៅប្រទេសកូរ៉េ

- បានទទួលជួបតំណាង JICA ពិភាក្សាពីគម្រោងសិក្សាអង្កេតពីភាពរីកចម្រើននៃសហគមន៍កសិកម្ម ដែលមានទីតាំងនៅជុំវិញខេត្តកំពង់ចាម

- បានបន្តសហការជាមួយ DTRA (Defence Threat Reduction Agency) បើកវគ្គបណ្តុះបណ្តាលនិស្សិតជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ

- បានពិសោធន៍សាកល្បងជីលើដំណាំបន្លែនៅឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

- បានធ្វើការពិសោធន៍ចិញ្ចឹមដង្កូវនាងព្រៃនៅក្នុងមន្ទីរពិសោធន៍

- បានរៀបចំជួសជុលផ្ទះសំណាញ់ដើម្បីរៀបចំធ្វើការពិសោធន៍ Hydroponic

- បន្តពិសោធន៍ចិញ្ចឹមនិងភ្ញាស់ដង្កូវនាងព្រៃ និងបញ្ជូនដង្កូវនាងព្រៃឱ្យសហគមន៍កសិកម្មចិញ្ចឹមចំនួន ១០គ្រួសារនៅឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

- បានរៀបចំពិសោធន៍បន្សុទ្ធពូជពោតដំណើបក្នុងស្រុក នៅច្បារពិសោធន៍

- បានចុះសិក្សាជំងឺលើដំណាំម្រេចនៅឃុំជុប ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

### ១២.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៦-២០១៧ សរុបមានចំនួន ៣ ៦៣៥នាក់ ចែកចេញជា ១០មហាវិទ្យាល័យគឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង និងថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមសម្រាប់ការបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បានដឹកនាំនិស្សិតចុះធ្វើកម្មសិក្សា និង ទស្សនកិច្ចសិក្សា នៅមូលដ្ឋានផលិតកម្ម រោងចក្រ សហគ្រាស និងតាមមន្ទីរកសិកម្មនានា ដើម្បីពង្រឹងសមត្ថភាពបន្ថែមទៀត

- បានចុះកិច្ចព្រមព្រៀងជាមួយសាកលវិទ្យាល័យ Guizhou University នៃសាធារណរដ្ឋប្រជាមានិតចិន លើការសិក្សាស្រាវជ្រាវរួមគ្នា ការផ្លាស់ប្តូរមន្ត្រី សាស្ត្រាចារ្យ និងនិស្សិត និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងចូលរួមក្នុងបណ្តាញសាកលវិទ្យាល័យកសិកម្មអាស៊ាន

- បានពិភាក្សាគ្នាក្នុងការបង្កើតកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសកសិកម្មទំនើបរបស់អ៊ីស្រាអែលដែលមានរយៈពេល២ឆ្នាំដំបូង ២០១៧-២០១៨ និងឆ្នាំបន្តបន្ទាប់

- បានពិភាក្សាជាមួយប្រតិភូសាកលវិទ្យាល័យហៃណាននៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្មត្រូពិចកម្ពុជា-ចិន

- បានទទួលធ្វើជាម្ចាស់ផ្ទះក្នុងការប្រារព្ធកម្មវិធីអន្តរជាតិប្រយុទ្ធប្រឆាំងនឹងភាពរហោស្ថានកម្ម។

## IV-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់ល្អប្រសើរនៅតាមរាជធានី ខេត្ត ទូទាំងប្រទេស ក៏ប៉ុន្តែនៅតាមបណ្តាខេត្តមួយចំនួនគឺទទួលរងនូវផលប៉ះពាល់ពីជំនន់ទឹកភ្លៀង និងការធ្លាក់ចុះនៃតម្លៃកសិផលជាដើម។ រីឯការងារបង្កបង្កើនផលដំណាំស្រូវវស្សាសម្រេចបានចំនួន ១ ២៦០ ២៨២ហ.ត ស្មើនឹង៥០,៤៨% នៃផែនការ ២ ៤៩៦ ៧៩០ហ.ត មានសភាពលឿនជាងឆ្នាំមុនប្រមាណ ២១៩ ៥៥៦ហ.ត (៨,៤៦%)។ ជាមួយនឹងការខិតខំប្រមូលផលដំណាំរដូវវស្សាយ៉ាងសស្រាក់សស្រាំរបស់បងប្អូនកសិករ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការនិងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងករណីមានគ្រោះរាំងស្ងួត ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ជាពិសេសកិច្ចសហការក្នុងការរៀបចំពិធីមច្ឆទិវា និងរុក្ខទិវាតាមប្រពៃណីក្នុងខែកក្កដានេះ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលាលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឲ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្តាញសង្គមផ្សេងៗ។ ដោយឡែកក្រសួងបានរៀបចំកិច្ចប្រជុំក្រុមការងារកសិកម្ម និងកសិ-ឧស្សាហកម្មដើម្បីចូលរួមចំណែកដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងឡាយដែលជាក្តីកង្វល់របស់វិស័យឯកជនរួមទាំងកសិករដែលចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។

## V- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវរដូវវស្សា និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៧-២០១៨ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំរួមផ្សំផ្សេងទៀតដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងកាត់បន្ថយការប្រើប្រាស់សារធាតុគីមី

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផលរដូវវស្សានេះ

- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះថ្លៃកសិផលផ្សេងៗជាយថាហេតុ ការងារសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋានក៏ដូចជាទីផ្សារកសិផលផ្សេងៗទៀតផងដែរ

- យកចិត្តទុកដាក់គិតគូរផ្សព្វផ្សាយអំពីការប្រើប្រាស់ជីកសិកម្ម ថ្នាំកសិកម្ម និងសារធាតុគីមីផ្សេងៗទៅលើផលិតផលកសិកម្មដែលនាំឲ្យប៉ះពាល់សុខុមាលភាពសាធារណៈ និងការនាំចេញកសិផលទៅក្រៅប្រទេស

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះផងដែរ។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និង ចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តរិះរកគ្រប់មធ្យោបាយដើម្បីចូលរួមដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងឡាយដែលបានលើកឡើងក្នុងក្របខណ្ឌនៃកិច្ចប្រជុំក្រុមការងារកសិកម្ម និងកសិ-ឧស្សាហកម្ម

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តាខេត្ត-រាជធានី និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ ជាពិសេសការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមតំបន់ដែលខ្សត់ទឹក

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិង ដំណាំចំណីសត្វនៅទូទាំងប្រទេស ព្រមទាំងជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបាន សមស្របតាមនីតិវិធី។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើសំខាន់ៗ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ សហគមន៍ព្រៃឈើ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជាលេខ០១ និង០២ របស់រាជរដ្ឋាភិបាលនិងចូលរួមអនុវត្តសេចក្តី

សម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព

- ត្រៀមរៀបចំរុក្ខទិវាដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៩ កក្កដា នៅភូមិក្រាំងក្រូច ឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាលនាពេលខាងមុខ។

**៤ ផ្នែកជលផល**:

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងគិតគូរអំពីមធ្យោបាយសង្គ្រោះធនធានមច្ឆជាតិនៅពេលឡើងកម្តៅខ្លាំងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃលិចទឹក

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៧ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គាក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោឱ្យបានសមស្របតាមវិធានបច្ចេកទេស ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ

- រៀបចំទិវាមច្ឆជាតិដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០១ កក្កដា នៅទំនប់សេកសក ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់ៗតាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំង

ការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តសហការជាមួយក្រសួងមុខងារសាធារណៈក្នុងការប្រឡងជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលសម្រាប់ឆ្នាំ២០១៧នេះ

- បន្តសហការរៀបចំច្បាប់ផ្សេងៗទៀត លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទតាមការចាំបាច់ និងលំដាប់អាទិភាព

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា រួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្មមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម៕

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**